**សុន្ទរកថា**

**ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម**

**ថ្លែងក្នុងឱកាសបើកសិក្ខាសាលាស្តីពី**

**ការពង្រឹងសមត្ថភាព និងតួនាទី របស់មន្ត្រីមន្ទីរពាណិជ្ជកម្មខេត្ត**

**សណ្ឋាគារ អង្គរហូលីដេ ខេត្តសៀមរាប**

ថ្ងៃទី២៥-២៩ ខែមករា ឆ្នាំ២០១០

ឯកឧត្តម លី គឹមសុខ នាយកសាលាភូមិន្ទរដ្ឋបាល

ឯកឧត្តម មាន សុភា ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និង ជាប្រធាននាយកដ្ឋាន ប្រព័ន្ធអនុគ្រោះទូទៅផ្នែកពាណិជ្ជកម្ម

ឯកឧត្តម ឈីវ យីស៊ាង នាយក ការសិក្សា និងកម្មសិក្សា សាលាភូមិន្ទរដ្ឋបាល

អ្នកស្រី នង រតនា តំណាង កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ

លោក លោកស្រី អ្នកនាង កញ្ញា ជាមន្ត្រីពាណិជ្ជកម្ម ខេត្តកំពង់ធំ ឧត្តរមានជ័យ ព្រះវិហារ និង ប៉ៃលិន

អង្គពិធីទាំងមូល ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយជាអនេក ដែលបានចូលរួមជាមួយឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដើម្បីថ្លែងបើកសិក្ខាសាលាស្តីអំពីការពង្រឹងសមត្ថភាព និងតួនាទីរបស់មន្ត្រីមន្ទីរ ពាណិជ្ជកម្ម រាជធានី-ខេត្ត ដែលនឹងប្រព្រឹត្តទៅរយៈពេល ០៥ ថ្ងៃខាងមុខនេះ ។ ឆ្លៀតក្នុងឱកាសដ៏កម្រ និងមានសារៈសំខាន់នេះ ក្នុងនាមឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង ខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូម ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះគំរោងជំនួយពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ និង សមធម៌ (TRADE Project) របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដែលបានផ្តល់មូលនិធិសម្រាប់បើកវគ្គសិក្ខាសាលា និង សូមថ្លែងអំណរគុណចំពោះសាលាភូមិន្ទរដ្ឋបាល ដែលបានចូលរួមសហការក្នុងការរៀបចំសិក្ខាសាលានេះឡើង ក្នុងគោលបំណងពង្រឹង សមត្ថភាពមន្ត្រីរាជការនៅមូលដ្ឋាន រាជធានី-ខេត្ត ឱ្យអនុវត្តបានជោគជ័យភារកិច្ច ដែលក្រសួងក៏ដូចរាជរដ្ឋាភិបាលប្រគល់ជូន។ តាមរយៈអង្គសិក្ខាសាលានេះសិក្ខាកាមនឹងទទួលបាននូវ បទពិសោធន៍ និងទស្សនទានថ្មីៗ ពីមន្ត្រី ជំនាញនៃក្រសួងពាណិជ្ជកម្ម។

**ឯកឧត្តម លោក លោកស្រី សិក្ខាកាម និង អ្នកចូលរួមទាំងអស់!**

នេះគឺជាលើកទី២ហើយ ដែលសាលាភូមិន្ទរដ្ឋបាល សហការជាមួយក្រសួងពាណិជ្ជកម្មរៀបចំវគ្គសិក្ខាសាលានេះឡើង ក្នុងនោះផងដែរ យើងកត់សំគាល់ឃើញថា គ្រប់នាយកដ្ឋានទាំងអស់នៃក្រសួងពាណិជ្ជកម្ម មានក្តីសោមនស្សរីករាយ និងឆន្ទៈក្នុងការចូលរួមចែករំលែកនូវចំណេះដឹង និងបទពិសោធន៍របស់ខ្លួនជូនដល់សិក្ខាកាម មកពីមន្ទីរពាណិជ្ជកម្មគ្រប់ រាជធានី-ខេត្ត ទាំងអស់របស់ក្រសួង។ ការបណ្តុះបណ្តាលធនធានមនុស្សគឺជាកំលាំងស្នូលដ៏សំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ ដើម្បីចិរភាព

និងវឌ្ឍភាព ដែលជាផ្នែកមួយក្នុងគោលនយោបាយចតុកោណរបស់ រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋម**ន្ត្រី ដែលយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះ វិស័យអប់រំដោយផ្តោតទៅលើគុណភាពជាចម្បង។

ជាមួយគ្នានេះដែល ក្រសួងពាណិជ្ជកម្មមានទទួល សេចក្តីសម្រេច ៧៦ ស.ស.រ. នៃរាជរដ្ឋាភិបាលកម្ពុជា ឡាយហត្ថលេខាដោយ សម្តេចនាយករដ្ឋមន្ត្រី ពីថ្ងៃទី១៤ធ្នូ ឆ្នាំ២០០៩ ឱ្យមានការបង្កើត គណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តមូលនិធិពហុភាគី និងសម្របសម្រួល អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade Sector Wide Approach) ដែលមានខ្ញុំជាប្រធាន និង ឯកឧត្តម លោកជំទាវ អស់លោកលោកស្រី តំណាងពីអន្តរក្រសួងមួយចំនួនដែលមានការពាក់ព័ន្ធក្នុងវិស័យពាណិជ្ជកម្ម ជាអនុប្រធាន និងជាសមាជិក ដែលក្នុងនុះ មាន ឯកឧត្តម នាយកសាលាភូមិន្ទរដ្ឋបាល ជាសមាជិកក្នុងគណៈកម្មការដែរ។ សេចក្តីសម្រេច នេះជាគោល តម្រូវឱ្យមានការបង្កើតក្រុមការងារ និង អនុវត្ត សសរស្តម្ភបី ដើម្បីជម្រុញការងារពាណិជ្ជកម្ម ជាកម្រង និងជាប្រព័ន្ធ។ សសរស្តម្ភទី១ **ការងារនិតិកម្ម និងបញ្ហាអន្តរវិស័យ** សសរស្តម្ភទី២ **ការងារអភិវឌ្ឍន៍សេវាកម្ម និងផលិតផលសម្រាប់ការនាំចេញ** សសរស្តម្ភទី៣ **ការងារអភិវឌ្ឍន៍សមត្ថភាពពាណិជ្ជកម្ម**។

សិក្ខាសាលាដែលយើងរៀបចំនេះ អាចរាប់បញ្ចូលក្នុងកិច្ចការរបស់ សសរស្តម្ភ ទី៣ ដែលមានភារៈកិច្ច មិនត្រឹមតែពង្រឹងនិងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីពាណិជ្ជកម្មនុះទេ ប៉ុន្តែមានភារៈកិច្ច បញ្ជ្រាបវិស័យពាណិជ្ជកម្ម ជាទូរទៅ ក្នុងផ្នែកសាធារណៈ ក៏ដូចជាផ្នែកឯកជន បង្កើនសមត្ថភាពមន្ត្រីដែលជាបុគ្គល ក៏ដូចជាសមត្ថភាព ស្ថាប័ន នានា ដូចជាផ្តល់ភាពយល់ដឹងដើម្បី ស្ថាប័ននីយកម្ម (institutionalization) ក្នុងស្ថាប័នបណ្តុះបណ្តាលមន្ត្រី ដែលមានជាអាតទ៍ សាលាភូមិន្ទរដ្ឋបាល ក្នុងការរៀបចំអប់រំ វិស័យពាណិជ្ជកម្មនៅមូលដ្ឋាន។

ថ្ងៃនេះយើងជួបជុំគ្នា រៀបចំសិក្ខាសាលាដើម្បីទទួលបាននូវ ធាតុថ្មីៗសម្រាប់ពង្រឹងសមត្ថភាពខ្លួនយើងផ្ទាល់ជាមូលដ្ឋាន និងឱ្យយល់កាន់តែច្បាស់អំពីតួនាទី ភារៈកិច្ចដែលត្រូវអនុវត្តឱ្យកាន់តែរលូន សមស្របតាមសភាពការណ៍ និងភាពប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្ម ក្នុងតំបន់ និងក្នុងពិភពលោកក្នុងពេលបច្ចុប្បន្ន។ ខ្ញុំសំណូមពរឱ្យសិក្ខាកាមរបស់យើងយកចិត្តទុកដាក់ស្តាប់បទឧទ្ទេសនាម និងធ្វើការ ពិភាក្សាឱ្យបានផុលផុស បន្ទាប់ពីទទួលបាននូវពុទ្ធិថ្មីៗ អំពីការឧទ្ទេសនាម និង ការពិភាក្សានៅពេលបន្តិចទៀតនេះ ខ្ញុំមានជំនឿថាសិក្ខាកាមទាំងអស់នឹងអាចបំពេញភារកិច្ច ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ដូច្នេះយើងសង្ឃឹមថា តាមរយៈការរៀនសូត្ររយៈពេល ០៥ ថ្ងៃនេះអាចផ្លាស់ប្តូរបទពិសោធន៍រវាងសិក្ខាកាម ជាមួយសិក្ខាកាម និងជាមួយអ្នកធ្វើបទឧទ្ទេសនាម ដែលឃើញថាមានផលប្រយោជន៍អាចយកមកអនុវត្តក្នុងការងារប្រចាំថ្ងៃបានល្អប្រសើរ និងសម្រាប់ការអភិវឌ្ឍនៃប្រទេសជាតិយើង។

សារជាថ្មីម្តងទៀត ខ្ញុំសូមជូនពរឱ្យអង្គសិក្ខាសាលានាពេលនេះ ប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា និង ទទួល បានលទ្ធផលដ៏ត្រចះត្រចង់។ សូមឯកឧត្តម លោក លោកស្រី អ្នកនាងកញ្ញា ទទួលបាននូវជោគជ័យ ក្នុងបេសកកម្មនិង ភារកិច្ចរបស់ខ្លួន។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាស្តីអំពី ការពង្រឹងសមត្ថភាព និងតួនាទី របស់មន្ត្រីមន្ទីរពាណិជ្ជកម្ម ខេត្ត ចាប់ពីពេលនេះតទៅ។

សូមអរគុណ